**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

*******

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ ៨៦

ចុះថ្ងៃទី៣០ខែមិនាឆ្នាំ១៩៩៩

សាលដីកា

លេខ : ២២៣

ចុះថ្ងៃទី២៦ខែតុលាឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ប្រធាន

២- លោក ម៉ែន ស៊ុន ចៅក្រម

៣- លោក សៀល មួន ចៅក្រម

៤- លោក ជីវ កេង ចៅក្រមរបាយការណ៍

៥- លោក ប្រាក់ គីមសាន ចៅក្រម

ក្រឡាបញ្ជី

លោក សុង ម៉ៅ

តំណាងមហាអយ្យការ

លោក ម៉ែន សាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧៤៥ ចុះថ្ងៃទី២៤ខែវិច្ឆិកាឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៤២ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ព្រំ កំាង ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅភូមិស្វាយព្រៃ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ព្រំ ឡែម " ស " ម្តាយឈ្មោះគ្រួច យាម " រ " ប្រពន្ធឈ្មោះកង ភឿន ។

មានមេធាវី លោកស្រី ស៊ិន សុវ៉ន ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ ពិន លាង ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅ ភូមិគោកចំបក់ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ ស្វាយ ពិន " រ " ម្តាយឈ្មោះឃី សឿម " រ " ប្រពន្ធឈ្មោះសុខ ឡុន។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំសិទ្ធិគ្រប់គ្រងដីមួយប្លង់ទំហំ ១៦ ,៧m × ៤៤ m

បានឃើញបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះ ព្រំ កាំង បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេច នៃសាលដីកាលេខ៧៤៥ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៩៦ ចុះថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២០_១១_៩៦ របស់ដើមចោទប្តឹងទាមទារសិទ្ធិគ្រប់គ្រងដី ១ឡូត៍ ទំហំ ១៦ ,៧ម × ៤៤ម ពីចុងចម្លើយឈ្មោះ ព្រំ កាំង ដោយសំអាងហេតុថា : ដីដែលមានទំនាស់នេះ ជាដីរបស់ខ្លួនពីសង្គមចាស់ ដែលមានដំណាំដូងស្វាយ លុះដល់ឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៩៤ ម្តាយរបស់ខ្លួនមកកាន់កាប់ និងគ្រប់គ្រងថែរក្សាដំណាំចាស់ ហើយថែមទាំងបេះភោគផលដំណាំទាំងនោះ ។ ក្រោយពីម្តាយក្មេកខ្លួនស្លាប់ទៅខ្លួនបានមកគ្រប់គ្រងជំនួស ដោយបានធ្វើពាក្យសុំកាន់កាប់ដីថ្មីក្នុងខែ ០៧ ឆ្នាំ១៩៩៦ លុះខែ ១១_១៩៩៦ ខ្លួនដឹកឈើទៅធ្វើផ្ទះលើដីទំនាស់ ស្រាប់តែចុងចម្លើយជំទាស់មិនឱ្យខ្លួនធ្វើ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារនៃ សេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ ទទួលស្គាល់ដីមួយកន្លែងស្ថិតនៅ ភូមិស្វាយព្រៃ ឃុំស្វាយដង្គុំ ស្រុកសៀមរាប ខេត្តសៀមរាប ដែលមានទំហំ ៥៤៧ ម២ គឺព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹងដី ព្រំ កាំង ខាងកើតទល់នឹងផ្លូវរទេះ និងខាងលិចទល់នឹង ហ៊ឹម សុវណ្ណ ឱ្យឈ្មោះ ពិន លាង មានសិទ្ធិកាន់កាប់ និង ប្រើប្រាស់ ។

៣_ សំរេចឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ បូករួម ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចស្រេចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យចុងចម្លើយសងប្រាក់ ៧.០០០៛ ទៅដើមចោទវិញ និងបង់ពន្ធសមាមាត្រមួយភាគរយលើមាស ១តម្លឹង បន្ថែមទៀត ដែលត្រូវដាក់ចូលថវិការដ្ឋ ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីក្នុងកម្ពុជា២០ភាគរយ ប្រាក់នេះ ត្រូវបង្គាប់ឱ្យដើមចោទបង់មុនដែរ ទើបបង្គាប់ឱ្យចុងចម្លើយបង់ជាក្រោយ ។

៤_ សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយបើកផ្លូវប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងពីសាលក្រមកំបាំងមុខ និង បើកផ្លូវឧទ្ធរណ៍កំណត់ ២ខែ គិតពីថ្ងៃសាលក្រមចូលចំពោះមុខ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ១៩៩៧ របស់លោក ព្រំ កាំង បានប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ៣២ ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៧ របស់តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ លើសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ៤០៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅៈ

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦_៥_៩៧ របស់ឈ្មោះព្រំ កាំង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣២ ចុះថ្ងៃទី ១៤_៣_៩៧ របស់តុលាការខេត្តសៀមរាប ទុកជាបានការដដែល ។

៣_ កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រ,០០ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធបណ្តឹង និងពន្ធចុះបញ្ជីក្តី ចំនួន២៥៥០រ,០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំនួន ៤៥០រ,០០ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ៥.០០០រ,០០ និងចំណាយលើអាជ្ញាធរតុលាការ ចំនួន ៥.០០០រ,០០ សរុប ១៣.០០០រ,០០ ។

៤_ សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៣៩ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៨ របស់ ព្រំ កាំង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៤០៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើវិនិច្ឆ័យសេចក្តី នៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៤៥ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅៈ

១_ ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ១៧_៨_៩៨ របស់ឈ្មោះព្រំ កាំង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២_ តំកល់សាលដីកាកំបាំងមុខលេខ ៤០៧ ចុះថ្ងៃទី ២០_៧_៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣_ សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែទុកដូចជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ១៩៩៩ របស់លោក ព្រំ កាំង បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៧៤៥ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើវិនិច្ឆ័យសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី ១៣_៨_១៩៩៩ របស់ឈ្មោះ ព្រំ កាំង

បានឃើញសារណាតបចុះថ្ងៃទី ១៨_៨_១៩៩៩ របស់ឈ្មោះ ពិន លាង

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា។
- សាលដីការដ្ឋប្បវេណីលេខ ៧៤៥ ចុះថ្ងៃទី ២៤_១១_៩៨ របស់សាលាឧទ្ធរណ៍ដែល បានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង អង្គច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ព្រំ កាំង ជាចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : ពីឆ្នាំ ១៩៧៩ មកមានឈ្មោះ ស៊ុន ឌី បានរស់លើដីនេះ ខ្លួនមានផ្ទះនៅពីក្រោយ ស៊ុន ឌី ដល់ឆ្នាំ ១៩៨២ ឈ្មោះ ស៊ុន ឌី ក៏ស្លាប់ ហើយបានប្រគល់ដីឱ្យ ឈ្មោះ ជិប ខាវ បន្តមរតក ដល់ឆ្នាំ១៩៨៦ ខ្លួនបានទិញដីនេះពី ជិប ខាវ ដោយឃើញជិប ខាវ បានទទួលផលលើដីនេះ កន្លងមក ។ ពេលទិញហើយ ខ្លួនក៏បានដាំដំណាំយកផលបំរើជីវភាពប្រចាំថ្ងៃ។ ពិន លាង នៅភូមិផ្សេងទេ រដ្ឋាភិបាលបានប្រកាសថា នរណានៅភូមិណាកាន់កាប់ដីភូមិនោះ វិញ ខ្លួនបានលិខិតទទួលស្គាល់ពីភូមិ_ឃុំ ប៉ុណ្ណោះ ក្រោយពីទិញបានបីបួនខែ ពិន លាង មកប្តឹងខ្លួន ។ មុនទិញដីនេះ ខ្លួនដឹងថា ស៊ុន ឌី ជាអ្នកកាន់កាប់រស់នៅ ក្រោយមកប្អូនថ្លៃ ស៊ុន ឌី ឈ្មោះ ជិប ខាវ បានគ្រប់គ្រងបន្តទៀត ។ ការទិញដីនេះមានលិខិតស្នាមត្រឹម ភូមិ_ឃុំ ធ្វើនៅខែមិថុនា ឆ្នាំ ១៩៨៦ មុនកើតរឿង ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ ពិន លាង ពេលជំនុំជំរះ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោកស្រីស៊ិន សុវ៉ន បញ្ជាក់ថា : ដីនេះ ពីមុន ស៊ុន ឌី គ្រប់គ្រងដល់ឆ្នាំ ១៩៨២ ឱ្យជិបខាវគ្រប់គ្រងបន្ត ដល់ឆ្នាំ១៩៨៦ ឈ្មោះពិន លាង ក្រោយពីស៊ុន ឌី ស្លាប់មិនដែលមានមុខទេ ។ ពេលខ្ញុំចុះទៅផ្ទាល់ប្រជាជនថា ដីនេះជារបស់ស៊ុន ឌី ការទិញដីរបស់ ព្រំ កាំង មានលិខិតស្នាមត្រឹមត្រូវ ក្រោយមក ៤ខែហើយ បាន ពិន លាង មក ឆា កូនក្តីខ្ញុំជាជនរងគ្រោះ ការទិញដីនេះក៏ស្របច្បាប់ ១ ,២ ,៣ នៃក្រិត្យ_ច្បាប់លេខ ៣៨ ក្រ.ច ឈ្មោះ ពិន លាង មិនបានមករស់នៅលើដីទំនាស់ទេ ហើយក៏មិនបានកាន់កាប់ដែរ ពាក្យកាន់កាប់របស់ ពិន លាង ធ្វើក្រោយការទិញដីរបស់កូនក្តីខ្ញុំ ។

សូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ និង សុំសិទ្ធិឱ្យកូនក្តីខ្ញុំបានកាន់កាប់ដីនេះជា កម្មសិទ្ធិតទៅ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់លោក ព្រំ កាំង សារណារបស់លោក ពិន លាង សេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣ ចុះថ្ងៃទី១៤_០១_៩៩ របស់លោកព្រំ កាំង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលលោក ព្រំ កាំង លើកឡើងនៅក្នុងសារណា ចុះថ្ងៃទី១៣ ៨_៩៩ របស់លោកថា ដីទំនាស់នេះ លោក ជឹប ខាវ បានគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦ ធ្វើឱ្យលោកមានសិទ្ធិលើដីទំនាស់នេះ តាមមាត្រា២ នៃ អនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី ២២_៤_៨៩ និង តាមមាត្រា ១៩ ,២០ និង ២១ នៃច្បាប់ភូមិបាលនោះជាការពុំត្រឹមត្រូវទេ ពីព្រោះលោកពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា លោក ពិតជាបានគ្រប់គ្រងដីទំនាស់នេះទេ សូម្បីតែរូបលោក ជឹប ខាវ ផ្ទាល់ក៏បានឆ្លើយនៅមុខមន្ត្រីយុត្តិធម៌ស្រុក និង រដ្ឋអំណាច ភូមិឃុំ កាលពីថ្ងៃទី ០៦_១១_៨៦ ថា ពេលខ្លួនលក់ដីឱ្យលោក ព្រំ កាំង ខ្លួនដឹងថា ដីទំនាស់នេះជារបស់តាសុខ និង យាយ ហ៊ិត ដែរ ។

- យល់ឃើញថា ការដែលលោក ព្រំ កាំង និង មេធាវីរបស់លោក លើកឡើងថា ការទិញដីទំនាស់នេះ ពីលោកជឹប ខាវ មានកិច្ចសន្យាត្រឹមត្រូវតាមមាត្រា១ ,២ ,៣ ,៣៤ និង៤១ នៃ ក្រឹត្យ_ច្បាប់លេខ ៣៨ ក្រច. ចុះថ្ងៃទី ២៨_១០_៨៨ ហើយ នោះជាការភាន់ច្រឡំ ពីព្រោះលោក ជឹប ខាវ មិនមែនជាម្ចាស់ដីទេ ដូច្នេះកិច្ចសន្យាលក់ទិញនេះ ត្រូវទុកជាមោឃៈតាមមាត្រា ៣៤ នៃ ក្រឹត្យ_ច្បាប់ ដដែលនេះហើយ ។

- យល់ឃើញថា ដើមចោទបានធ្វើសារណាការពាររឿងក្តីរបស់លោក ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះ កំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការជួបប្រជុំលើលេខ៧៤៥ ចុះថ្ងៃទី ២៤_១១_៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខលោកព្រំ កាំង កំបាំងមុខលោកពិន លាង**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១_ ទទួលបណ្តឹងសាទុក្ខលេខ ២៣ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៩ របស់ លោក ព្រំ កាំង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលដីការដ្ឋប្បវេណីលេខ ៧៤៥ ចុះថ្ងៃទី ២៤_១១_៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោក ព្រំ កាំង បានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់
- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

បង្គាប់ឱ្យលោក ព្រំ កាំង បង់ពន្ធសមាមាត្រ តាមការកំណត់ របស់តុលាការខេត្ត សៀមរាប ។

៤_ សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលាឆ្នាំ២០០០។